ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៣៣

ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៤

សាលដីកា

លេខ: ៨១

ចុះថ្ងៃទី១២ខែតុលាឆ្នាំ២០០៥

# នាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៥ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ:

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ប្រធាន

២- លោក ឃឹម ស៊ីផល ចៅក្រម

៣- លោក យស់ សួខឿន ចៅក្រម

៤- លោក វៀល មួន ចៅក្រម

៥- លោក ប៉ែន សារឿន ចៅក្រម

ក្រឡាបញ្ជី

លោក សាន សុផាត

**តំណាងមហាអយ្យការ**

លោក ឈួន ចាន់ថា ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៦៧"ក" ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៣៣ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

**<u>ចំពោះ</u>:** មនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅភូមិផ្សារថ្មី ឃុំពាមប្រធ្នោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៩៩ បទល្មើសដែលមានចែងតាមមាត្រា៤០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ជនជាប់ចោទឈ្មោះសុខ ទិត្យ (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ របររកស៊ីគ្រូពេទ្យ មានទីលំនៅសព្វថ្ងៃ ភូមិផ្សារថ្មី ឃុំពាមប្រធ្នោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម ។ ឪពុកឈ្មោះគល់ សុខ (រ) ម្តាយឈ្មោះ ប៉ុល គង (ស) ប្រពន្ធឈ្មោះព្រំ សារ៉េន មានកូន០៥នាក់ ។ ក្រៅឃុំ ។

-មេធាវី : លោក កែ ចំរើន

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ឯម សឿន (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥៥ឆ្នាំ ជាតិខ្មែរ

របររកស៊ី ធ្វើចំការ ទីលំនៅសព្វថ្ងៃ ភូមិផ្សារថ្មី ឃុំពាមប្រធ្នោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម ។

-តាមពាក្យបណ្តឹងចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០០ របស់ឈ្មោះ ឯម សឿន ថា កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៩៩ ប្រពន្ធខ្លួនបានអញ្ជើញពេទ្យឈ្មោះ សុខ ទិត្យ ដើម្បីមកព្យាបាលជំងឺឱ្យកូនទាំងពីរនាក់មានជំងឺ :

- កូនទី១ ឈ្មោះ សឿន សូលីកា ភេទស្រី អាយុ១១ឆ្នាំ

- កូនទី២ ឈ្មោះ សឿន ម៉ារ៉ឌី ភេទប្រុស អាយុ១៥ឆ្នាំ

ពេទ្យ សុខ ទិត្យ ចាប់ព្យាបាលជំងឺ ពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៩៩ ដល់ថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩៩ ។ រយៈពេលនៃការព្យាបាលថ្ងៃទី៤ គ្រូពេទ្យបានជូសឈាមទាំងពីរនាក់យកពិនិត្យ ហើយថ្ងៃទី៥ ទើបបានបង្ហាញលទ្ធផលឈាម។ ដល់ថ្ងៃទី៦ ( ថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៩ ) គ្រូពេទ្យឈ្មោះសុខ ទិត្យ បានព្យួរសេរ៉ូមអោយអ្នកជំងឺ រហូតដល់ថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩៩ ។ ព្យួរសេរ៉ូមក្នុងម្នាក់៤ប្លោក នៅយប់ថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៩៩ វេលាម៉ោង១២.៣០នាទី កូនស្រីខ្លួនឈ្មោះ សឿន សូលីកា បានស្លាប់ ក្រោយពេលគ្រូពេទ្យដកសេរ៉ូមចេញ.ឯកូនប្រុសខ្លួនស្លាប់នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៩៩ ម៉ោង៦.៣០ព្រឹក។ ខ្លួនសុំប្តឹងឱ្យតុលាការផ្តន្ទាទោសឈ្មោះសុខ ទិត្យ តាមច្បាប់ និង សុំទាមទារជំងឺចិត្ត ថ្លៃបាត់បង់កូនទាំងពីរចំនួនទឹកប្រាក់ ១០០០០( មួយម៉ឺនដុល្លារអាមេរិក) ។

-បានឃើញដីកាសំរេចតម្កល់រឿងឥតចាត់ការលេខ០៥ អក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០១ របស់អយ្យការ អមតុលាការខេត្តកំពង់ចាម ដែលបានសំរេច :

រឿងនេះមិនចូលជាបទល្មើសព្រហ្មទណ្ឌ តាមលិខិតរបស់លោកអ៊ុង សួរ អនុប្រធានមណ្ឌលសុខ ភាពពាមប្រធ្នោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម លេខ៥៥/២០០១ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០១ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៣៣ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០១ របស់ឈ្មោះ ឯម សឿន តវ៉ាមិនសុខចិត្តពីដីកាសំរេចលេខ០៥ អក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០១ របស់អយ្យការ អមតុលាការខេត្តកំពង់ចាម លើដីកាសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា:

១-ទទួលសេចក្តីប្តឹងតវ៉ាលេខ៣៣ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០១ របស់ឈ្មោះឯម សឿន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុស នឹង គតិច្បាប់ ។

២-តំកល់ដីកាសំរេចលេខ០៥ អក ចុះថ្ងៃទី៣១ ខែមេសា ឆ្នាំ២០០១របស់តំណាងអយ្យការខេត្តកំពង់ចាមទុកជាបានការ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៦៧"ក" ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសំរេច:

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០១ របស់ឈ្មោះឯម សឿន ទុកជាត្រឹមត្រូវតាមទំរង់ តែបដិសេធចោលដោយទាស់ នឹង គតិច្បាប់ ។

២-តំកល់ដីកាតំកល់រឿងទុកឥតចាត់ការលេខ០៥ អក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០១ របស់អយ្យការ អមតុលាការខេត្តកំពង់ចាមដដែល ។

៣-សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈកំបាំងមុខជនជាប់ចោទនិងដើមបណ្តឹងរដ្ឋប្បវេណី បើផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ១០៩ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៣ របស់ឈ្មោះ ឯម សឿន តវ៉ាមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ៦៧ ក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណា ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៤ របស់ឈ្មោះ ឯម សឿន (ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់ ។

-បានឃើញសារណាតប ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៤ របស់ឈ្មោះ សុខ ទិត្យ (ជាចុងបណ្តឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់ ។

-បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា: សាលដីកាសាលាឧទ្ធរណ៍សំរេចសេចក្តីមកនេះ ពុំមានលក្ខណៈត្រឹមត្រូវឡើយ ។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ ឯម សឿន (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា: សាលាឧទ្ធរណ៍សំរេចសេចក្តីកំបាំងមុខខ្ញុំបាទ សំរេចតាមតុលាការកំពង់ចាម ខ្ញុំបាទមិនសុខចិត្តទេ ព្រោះកូនខ្ញុំទាំង២នាក់ត្រូវស្លាប់ ។ ព្យាបាលអស់រយៈពេល៩ថ្ងៃ ថ្ងៃទីមួយរហូតដល់ថ្ងៃទីប្រាំ កូនខ្ញុំមានសភាពធូរស្បើយ ប៉ុន្តែដល់ថ្ងៃទីប្រាំមួយ ឈ្មោះសុខ ទិត្យ ជួសឈាមកូនខ្ញុំទៅពិនិត្យស្រាប់តែអ្នកជំងឺធ្លាក់ខ្លួនស្លាប់តែម្តង ។ មូលហេតុខ្ញុំបាទយឺតយ៉ាវក្នុងការប្តឹងព្រោះ សុខ ទិត្យ សុំអង្វរកុំឱ្យប្តឹង ដោយខ្លួនសុំចេញលុយខ្លះ ប៉ុន្តែឈ្មោះ សុខ ទិត្យ ពុំបានចេញលុយឱ្យខ្ញុំទេ ។ ដូច្នេះ ខ្ញុំសូមប្តឹងទាមទារជំងឺចិត្ត១ម៉ឺនដុល្លា ។

-បានស្តាប់ក្រឡាបញ្ជីអានសាវតាជាតិ និង សារណារបស់ឈ្មោះ សុខ ទិត្យ ។

-បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់លោក កែ ចំរើន ជាមេធាវីការពារជនជាប់ចោទឈ្មោះ សុខ ទិត្យ (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា: សុខ ទិត្យ ជាគ្រូពេទ្យមានការទទួលខុសត្រូវ គាត់ធ្វើពេទ្យ តាំងពីឆ្នាំ១៩៩៩ ពិនិត្យអ្នកជំងឺពុំដែលមានការធ្វេសប្រហែសទេ ។ មុនពេលស្លាប់២ថ្ងៃ កូនក្តីខ្ញុំបានប្រាប់ឱ្យលោក ឯម សឿន យកកូនទៅពេទ្យខេត្តពិនិត្យទៀត ប៉ុន្តែពុំទាន់បានទៅផង អ្នកជំងឺស្រាប់តែស្លាប់តែម្តង ។ កូនក្តីខ្ញុំពុំមានកំហុសទេ សូមតម្កល់សាលដីកាសាលាឧទ្ធរណ៍ ទុកជាបានការ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមនាពេលសវនាការ របស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា: ដីកាតម្កល់រឿងទុកឥតចាត់ការនេះ ពុំបានសង្កេតឱ្យបានត្រឹមត្រូវ ព្រោះអ្នកជំងឺស្លាប់ក្នុងដៃគ្រូពេទ្យ រឺ ស្លាប់ក្នុងដៃឪពុកម្តាយ សូមក្រុមប្រឹក្សា មេត្តាសំរេច ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី សារណារបស់ឈ្មោះ សុខ ទិត្យ និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីរបស់ឈ្មោះ សុខ ទិត្យ ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១០៩ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៣ របស់លោក ឯម សឿន ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ក៏ដូចអយ្យការ អមតុលាការខេត្តកំពង់ចាមដែរ ដែលតម្កល់រឿងមរណៈភាពនៃកុមារទាំងពីរនាក់នេះ ពុំចាត់ការនោះជាការពុំត្រឹមត្រូវទេ ពីព្រោះថា ពុំទាន់មានភស្តុតាងណាមួយបញ្ជាក់ថា មរណៈភាពនៃកុមារទាំងពីរជាមរណៈភាព តាមសភាវៈនៃអ្នកជំងឺ ឬ បណ្តាលមកពីការធ្វេសប្រហែសជាបទអាជ្ញារបស់អ្នកព្យាបាល ឬ អណាព្យាបាលឡើយ ។

-យល់ឃើញថា ឈ្មោះសុខ ទិត្យបានធ្វើសារណាការពារក្តីរបស់ខ្លួនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានចូលខ្លួននាពេលសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៦៧"ក"ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខមេធាវី ជនជាប់ចោទ និង**

**ដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ តែចាត់ទុកជាចំពោះមុខ :**

១-ទទួលបណ្តឹងសាទុក្ខលេខ១០៩ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៣ របស់ឈ្មោះឯម សឿន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ៦៧"ក" ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ៣៣ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៤ របស់តុលាការកំពូលទៅអយ្យការ អមតុលាការខេត្តកំពង់ចាម ដើម្បីចាត់ការបន្ត ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៥ ។